## លក្ខណៈធម្មជាតិនៃ
# ព្យាការី យេស៊ូ

*ដើម្បីយល់ពីលក្ខណៈរបស់ព្រះក្នុងសាសនាអ៊ីស្លាម ចាំបាច់ត្រូវពិភាក្សាពីសភាពរបស់លោកយេស៊ូ ដែលកំពុងផ្សព្វផ្សាយទាំងមានការយល់ច្រឡំនិងការអះអាងពីធម្មជាតិរបស់លោកយេស៊ូ។*

គ្រីស្ទបរិស័ទខ្លះអះអាងថា*លោកយេស៊ូគឺជាព្រះ* ឬជាផ្នែកមួយនៃព្រះត្រីឯក និងជាព្រះដែលចុះមកផែនដីនេះក្នុងសភាពជាមនុស្ស។ យ៉ាងណាមិញ បើយោងតាមគម្ពីរបរិសុទ្ធ(ប៊ីប) លោកយេស៊ូបានប្រសូត, លោកញ៉ាំអាហារ, សម្រាន្ត, អធិដ្ឋានថ្វាយបង្គំព្រះ រីឯចំណេះដឹងរបស់លោកមានកំណត់។ ការសន្មត់ទាំងអស់នេះលោកមិនសមល្មមជាព្រះនោះទេ។ ការសន្មត់ចំពោះព្រះគឺល្អឯក រីឯមនុស្សវិញគឺផ្ទុយពីនោះ។ ដូច្នេះតើមានអ្វីដែលអាចទៅរួចក្នុងការល្អឯកផង និងមិនល្អឯកផងក្នុងពេលតែមួយនោះ? គ្មានហេតុផលសមទំនងនោះទេ។

យ៉ាងណាមិញអ្នកខ្លះនឹងសួរថា "បើព្រះអាចធ្វើអ្វីបានគ្រប់យ៉ាង រឿងអីដែលព្រះមិនអាចជាមនុស្សបាន?" ឆ្លើយតាមការកំណត់សេចក្តីថា ព្រះទ្រង់មិនធ្វើអ្វីដែលមិនមានលក្ខណៈជាព្រះនោះទេ។ ដូច្នេះបើព្រះក្លាយជាមនុស្ស ហើយទទួលបានសន្មត់តាមបែបមនុស្សនោះ ទ្រង់មិនមែនជាព្រះទៀតនោះឡើយ។

កាន់តែស៊ីជម្រៅទៅទៀត គម្ពីរបរិសុទ្ធ(ប៊ីប) ផ្ទុកនូវ ខ ជាច្រើនដែលលោកយេស៊ូបានមានប្រសាសន៍ និងឥរិយាបទរបស់លោក។ ជាឧទាហរណ៍៖ លោកយេស៊ូ ក្រាបមុខដល់ដីរួចអធិដ្ឋាន (ម៉ាថាយ ២៦:៣៩) ។ ប្រសិនបើលោកយេស៊ូជាព្រះនោះ ហេតុអ្វីបានជាលោកក្រាបមុខដល់ដីរួចអធិដ្ឋាន? ហើយតើនរណាដែលលោកយេស៊ូអធិដ្ឋានទៅកាន់នោះ?

គ្រីស្ទបរិស័ទខ្លះទៀតអះអាងថា "លោកយេស៊ូជាបុត្ររបស់ព្រះ" យើងគួរតែសួរខ្លួនឯងថា តើនេះមានន័យដូចម្តេច? ប្រាកដណាស់ព្រះទ្រង់នៅឆ្ងាយណាស់ពីការមានបុត្របង្កើតដែលមានលក្ខណៈរូបនោះ។ ជាមួយគ្នានេះដែរយើងឃើញថាពាក្យ"បុត្រនៃព្រះ" ជាពាក្យសំគាល់ដែលប្រើប្រាស់ក្នុងគម្ពីរបរិសុទ្ធកាលពីសម័យមុន សម្តៅដល់ "មនុស្សសុចរិត" ។ ពាក្យនេះត្រូវបានប្រើប្រាស់ទូទៅក្នុងគម្ពីរសញ្ញាណចាស់ សម្តៅដល់មនុស្សសុចរិតដូចជា ស្តេចដាវីឌ , ស្តេចសាឡូម៉ូន, លោកអ៊ីស្រាអែល ជាដើម មិនប្រើផ្តាច់មុខចំពោះតែលោកយេស៊ូម្នាក់ទេ ឧទាហរណ៍ជាក់ស្តែង៖ អ៊ីស្រាអែល គឺជាបុត្រច្បងរបស់យើង (និក្ខមនំ ៤:២២)។

សេចក្តីជំនឿនៃសាសនាអ៊ីស្លាម ទទួលជឿលើលោកយេស៊ូក្នុងលក្ខណៈពិតរបស់លោក។ ទន្ទឹមគ្នានោះដែរក៏រក្សានូវជំនឿលើព្រះ និងការណ៍អស្ចារ្យ, លក្ខណៈឯក និងលក្ខណៈល្អប្រសើររបស់លោកយេស៊ូ។ លោកយេស៊ូក៏ជាព្យាការីដែលត្រូវបានគេលើកតម្កើងមួយរូប ដែលព្រះបានបញ្ជូនមក ដើម្បីអំពាវនាវទៅកាន់មនុស្សជាតិ អោយគោរពសក្ការៈទៅកាន់ព្រះតែមួយអង្គគត់។

*"មិនសាកសមនោះឡើយ សម្រាប់អល់ឡោះដែលថាទ្រង់មានបុត្រនោះ ទ្រង់មហាស្អាតស្អំ"*

*-អាល់គួរអាន ១៩:៣៥*

# តើហេតុអ្វីខ្ញុំមកទីនេះ?

មនុស្សគ្រប់គ្នាសុទ្ធតែបានយល់ដឹងពីសរីរាង្គរបស់ខ្លួនដូចជា ភ្នែក, ត្រចៀក, ខួរក្បាល និងបេះដូង ពួកសុទ្ធត្រូវបានបង្កើតមកដោយមានគោលបំណង។ ដូច្នេះតើមិនសមហេតុផលឬទេ បើសរីរាង្គនីមួយៗសុទ្ធតែមានគោលបំណង នោះរូបកាយយើងទាំងមូលក៏ដូចគ្នាដែរមែនទេ?

ព្រះដែលមានគ្រប់បញ្ញាញាណទ្រង់មិនបានបង្កើតមនុស្សយើងអោយរសាត់អណ្តែតគ្មានគោលដៅ ឬគ្រាន់តែអោយមនុស្សបំពេញតម្រូវការសាមញ្ញៗរបស់ខ្លួនឡើយ។ ជាក់-ស្តែងណាស់ យើងមានគោលបំណងខ្ពស់ជាងនេះ គឺការយល់ដឹង និងគោរពសក្ការៈព្រះតែមួយអង្គគត់ នោះយើងនឹងបានរស់នៅក្រោមការចង្អុលបង្ហាញពីអ្នកដែលបង្កើតយើង ទ្រង់ប្រទានអោយយើងអាចរស់នៅដោយភាពជោគជ័យ និងការប្រទានពរក្នុងជីវិត។ រួមបញ្ចូលទាំងកិច្ចការគុណធម៌ផ្សេងខ្លួនដូចជាការអធិដ្ឋានថ្វាយបង្គំ(សឡាហ៍), កិច្ចការដែលផ្តល់ផលប្រយោជន៍ដល់សង្គម ដូចជាការធ្វើល្អទៅចំពោះអ្នកជិតខាង, ទំនុកបម្រុងក្រុមគ្រួសារ, សេចក្តីស្មោះត្រង់ និងការថែរក្សាសត្វជាដើម។

ព្រះទ្រង់ហាមប្រាមយើងពីការគោរពសក្ការៈចំពោះអ្វីផ្សេងទៀត (ដូចជា រូបចម្លាក់,ព្រះ-អាទិត្យ, ព្រះច័ន្ទ, សន្តបុគ្គល, បព្វជិត និងសូម្បីតែពួកព្យាការី)។ ទ្រង់ពុំត្រូវការគួរកនឬអន្តរការីឡើយ។ មនុស្សគ្រប់គ្នាអាចគោរពសក្ការៈទៅចំពោះទ្រង់ដោយផ្ទាល់។

ព្រះទ្រង់បរិយាយអំពីជីវិតមនុស្សថាជាការល្បង មនុស្សទទួលបានការល្បងខុសៗពីគ្នា យើងមិនអាចរារាំងនូវអ្វីដែលកើតឡើងចំពោះយើងបានឡើយ ប៉ុន្តែយើងអាចត្រៀមខ្លួនឯងសម្រាប់ប្រឈមមុខនឹងរឿងនោះ។ អត់ធ្មត់ចំពោះការខ្វះខាត, ដឹងព្រះគុណដើម្បីទទួលបាននូវពរ គឺមានន័យថាចូលកាន់តែជិតព្រះ និងចូលទៅកាន់ស្ថានបរមសុខជាអនន្តកាល។ យើងក៏ទទួលបានការព្រមានពីទណ្ឌកម្មនៃស្ថាននរក ប្រសិនបើយើងជ្រើសយកការគ្មានជំនឿ និងបដិសេធការបង្គាប់ប្រើរបស់ទ្រង់។

# តើខ្ញុំត្រូវធ្វើអ្វីពេលនេះ?

ការល្បងចំពោះ ជំនឿតែមួយគត់ គឺត្រូវប្រើបញ្ញាញាណក្នុងការសញ្ជឹងគិត និងសម្គាល់ដឹងពីសញ្ញានានារបស់ព្រះ ហើយរស់នៅតាមការចង្អុលបង្ហាញរបស់ទ្រង់។ រឿងនេះធ្វើទៅបានដោយ*ថ្វាយខ្លួនទៅចំពោះព្រះ* ដែលភាសាអារ៉ាប់ហៅការណ៍នេះថា *មូស្លីម* ។ ព្រះជាអ្នកបង្កើតតែមួយអង្គគត់ ភាសាអារ៉ាប់គឺ*អល់ឡោះ* ។ ទ្រង់បង្កើតសាសនាអ៊ីស្លាមអោយទៅក្បៀកជិតនឹងមនុស្សគ្រប់រូបដោយមិនគិតពីអតីតកាលឬបច្ចុប្បន្នភាពរបស់ពួកគេ។ ទន្ទឹមនឹងនេះដែរ មនុស្សគ្រប់រូបអាចក្លាយជា មូស្លីម ដោយគ្រាន់តែមានជំនឿនិងបន្លឺនូវពាក្យដែលបង្ហាញពីសក្ខីភាពនៃជំនឿថា៖

> *"ខ្ញុំសូមធ្វើសាក្សីថាគ្មានព្រះឯណាឡើយដែលត្រូវគោរពសក្ការៈផ្សេងពីអល់ឡោះ ហើយខ្ញុំសូមធ្វើសាក្សីទៀតថា មូហាំម៉ាត់ គឺជាសារហារីនៃអល់ឡោះ"*

តើនេះមិនមែនជាពេលដែលអ្នកត្រូវបំពេញនូវគោលបំណងនៃជីវិត, ចុះចូលក្នុងសេចក្តីពិត និងទទួលស្គាល់អ្នកដែលបង្កើតអ្នកទេឬ?

: Al-Peac : al_peac : AL-PEAC Cambodia

# តើអ្វីជា គោលបំណង នៃជីវិត?

*តើខ្ញុំមកពីណា?*

*ហេតុអ្វីខ្ញុំមកទីនេះ?*

*តើខ្ញុំកំពុងទៅណា?*



AL-PEAC
ALLAH LOVES CAMBODIA

# តើអ្វីជា គោលបំណង នៃជីវិត?

សំណួរដំបូងបង្អស់ដែលយើងគិតដល់មុនគេ នៅពេលដែលយើងពិចារណាអំពីគោលបំណងនៃជីវិតរបស់យើងគឺ *តើយើងមកពីណា?* តើយើងពិតជាកើតឡើងដោយឯកឯងពីធម្មជាតិ ឬក៏មានបញ្ញាញាណដ៏ក្រៃលែងមួយជាអ្នកបង្កើតយើង? ប្រាកដណាស់ មានហេតុផលឡូហ្សិក(តក្កៈ) និង សមទំនងជាច្រើនដែលអាចនាំយើងអោយជឿថាមានអ្នកបង្កើតពិតមែន។ ខាងក្រោមនេះគឺជាហេតុផល៣យ៉ាង ដែលរៀបរាប់ដោយសង្ខេប។

## 1.កំណកំណើតនៃ សាកលលោក

ភស្តុតាងដំបូងដែលអាចបង្ហាញអោយយើងឃើញពីវត្តមានរបស់អ្នកបង្កើតនោះគឺការស្វែងយល់អោយបានច្បាស់ពីកំណកំណើតនៃសាកលលោក។

ចូរអ្នកសាកស្រមៃថាអ្នករើសបាននាឡិកានៅលើវាលខ្សាច់មួយ។ ដូចដែលយើងដឹងហើយថា នាឡិកាផ្សុំឡើងពីវត្ថុធាតុដើមដូចជា៖កញ្ចក់, ផ្លាស្ទិក និងលោហៈ។ កញ្ចក់ផលិតមកពីខ្សាច់ ផ្លាស្ទិកផលិតពីប្រេង និងលោហៈយកចេញមកពីក្នុងដី។ វត្ថុធាតុដើមទាំងអស់នេះគឺសុទ្ធតែអាចរកបាននៅលើវាលខ្សាច់។ តើលោកអ្នកជឿទេថានាឡិកានេះវិវត្តន៍មកពីធម្មជាតិដោយឯកឯង? ឬក៏ដោយសារព្រះអាទិត្យជះកម្ដៅ បន្ទាប់មកមានខ្យល់បោកបក់រួចមានរន្ទះបាញ់ ប្រេងក៏ផុលឡើងមកលាយជាមួយខ្សាច់និងលោហៈ ធាតុភូតនេះកើតឡើងដដែលៗអស់រាប់លានឆ្នាំ ក្រោយមកវិវត្តន៍ក្លាយជានាឡិកាដោយឯកឯង?

> *អ្នកខ្លះសួរថា ចុះតើនរណាបង្កើតព្រះ? ព្រះទ្រង់ជាអ្នកបង្កើត គឺខុសពីអ្វីដែលទ្រង់បានបង្កើត, ទ្រង់គង់នៅជាអនន្តកាល, ទ្រង់គង់នៅជានិច្ច គ្មានទីផ្ដើម និង គ្មានទីបញ្ចប់។*

អ្វីដែលមនុស្សបានជួបប្រទះ រួមទាំងឡូហ្សិកសាមញ្ញៗ បានបង្ហាញអោយយើងដឹងថា គ្មានអ្វីមួយដែលកើតឡើងពីភាពទទេរនោះទេ ហើយក៏គ្មានអ្វីមួយអាចបង្កើតខ្លួនឯងនោះដែរ។ ទន្ទឹមគ្នានេះដែរ ហេតុផលដែលសមទំនងជាងគេគឺ ប្រាកដជាមាន*អង្គ* ដ៏ខ្ពង់ខ្ពស់មួយជាអ្នកបង្កើតសាកលលោកនេះ។ *អង្គ* នេះគឺត្រូវតែមានថាមពល និងបញ្ញាញាណដ៏ក្រៃលែង លើសពីអ្វីៗលើលោក ហើយក៏បង្ករបង្កើតនូវ "ច្បាប់នៃវិទ្យាសាស្រ្ត" ដែលគ្រប់គ្រងលោកនេះ។ យើងក៏អាចផ្ដល់ហេតុផលបន្ថែមទៀតថា *អង្គ* នេះមិនរសាត់អណ្ដែតក្នុងលំហរឡើយ ពីព្រោះ ពេលវេលា, លំហ និងរូបធាតុ កើតមាននៅពេលកកើតសាកលលោក។ ការសន្និដ្ឋានទាំងនេះ បង្កើតបាននូវលក្ខណៈជាមូលដ្ឋានរបស់*ព្រះ* ដែលជាអ្នកបង្កើតនូវសាកលលោកនេះ។ នេះគឺជាការចុះសម្រុងជាមួយនឹងវិទ្យាសាស្រ្តយ៉ាងល្អបំផុត ដែលសម្រេចថាសាកលលោកគឺមានកាលកំណត់ និងមានការចាប់ផ្ដើម។

## 2.ភាពឥតខ្ចោះនៃ សាកលលោក

ភស្តុតាងទី ២ ដែលបង្ហាញអោយយើងដឹងពីវត្តមាននៃ *ព្រះ* ដែលជាអ្នកបង្កើតប្រកបដោយព្រះបញ្ញាញាណនោះគឺ ភាពរៀបរយ និងតុល្យភាពយ៉ាងឥតខ្ចោះ នៃសាកលលោកដ៏ស្មុគស្មាញ ដែលយើងកំពុងរស់នៅនេះ។

លក្ខណៈពិសេសជាច្រើននៃសាកលលោកនេះ បង្ហាញយ៉ាងច្បាស់ថាវាពិតជាត្រូវបានរចនាឡើងជាពិសេសសម្រាប់ទ្រទ្រង់ជីវិត។ មានដូចជា ចម្ងាយរវាងផែនដីនិងព្រះអាទិត្យ, កម្រាស់នៃស្រទាប់ផែនដី, ល្បឿននៃវង្វិលផែនដី, ភាគរយនៃឧស្ម័នអុកស៊ីសែន និងភាគរយនៃសម្ពាធ, រួមទាំងភាពទ្រេតនៃផែនដីផងដែរ។ ប្រសិនបើរង្វាស់រង្វាល់ណាមួយ ខុសគ្នាតែបន្តិចពីរង្វាស់រង្វាល់បច្ចុប្បន្ន នោះជីវិតមិនអាចកកើតបានឡើយ។

មិនខុសគ្នាទេប្រសិនបើនាឡិកាពិតជាមានអ្នកបង្កើតដែលមានបញ្ញាម្នាក់ ដើម្បីអោយម៉ោងដើរសុក្រឹតត្រឹមត្រូវនោះផែនដីគឺត្រូវតែមានអ្នកបង្កើតដែលមានបញ្ញាញាណ ដើម្បីអោយការវិលជុំវិញព្រះអាទិត្យមានពេលវេលាសុក្រឹតត្រឹមត្រូវដែរ។ តើវាអាចកើតឡើងដោយខ្លួនឯងឬទេ?

> *"ជាការប្រាកដណាស់ ការបង្កើតមេឃ និងដី ហើយការផ្លាស់ប្ដូររវាងយប់និងថ្ងៃ គឺជាភស្តុតាងយ៉ាងច្បាស់លាស់សម្រាប់ពួកបញ្ញាជន"*
> *-អាល់គួរអាន ៣ : ១៩០*

នៅពេលយើងឃើញអ្វីមួយដែលមានភាពរៀបរយ, មានបញ្ញត្តិនិងប្រព័ន្ធជាក់លាក់ ដូចជានៅក្នុងខ្លួនយើងផ្ទាល់ ហើយនិងសាកលលោកទូទៅ តើមិនសមហេតុផលទេឬ ដែលមានអ្នករៀបចំនោះ? ជាថ្មីម្ដងទៀត *អ្នកដែលរៀបចំ*នេះ គឺជាការបកស្រាយដ៏សមហេតុផលបំផុតនៃ *ព្រះ* ដែលជាអ្នករៀបចំអោយយើងមានការរៀបរយត្រឹមត្រូវ។

## 3.ការបើកបង្ហាញពី ព្រះ

ភស្តុតាងទី ៣ ដែលបង្ហាញអោយយើងឃើញពីវត្តមាននៃព្រះដែលជាអ្នកបង្កើតនោះ គឺ ការបើកបង្ហាញជាក់ស្ដែងដែលទ្រង់បានបញ្ចុះមកកាន់មនុស្សជាតិ ជាសញ្ញាអោយដឹងពីវត្តមានរបស់ទ្រង់។

> *ប្រសិនបើ ព្រះបើកបង្ហាញនូវកម្ពីនៃការចង្អុលបង្ហាញនោះ យើងជឿជាក់ថា នឹងមានផ្ទុកនូវភស្តុតាងយ៉ាងជាក់ច្បាស់ពីវត្តមាននៃព្រះ។*

មានសញ្ញាបង្ហាញច្បាស់ថាគម្ពីរអាល់គួរអាននៃសាសនាអ៊ីស្លាម គឺជាព្រះបន្ទូលនៃព្រះ។ ខាងក្រោមនេះជាហេតុផលសង្ខេបដើម្បីគាំទ្រការអះអាងនេះ។ *គម្ពីរអាល់គួរអាន៖*

- មានអាយុជាង១៤០០ឆ្នាំផ្ទុកទៅដោយព័ត៌មានវិទ្យាសាស្រ្តដែលមនុស្សសម័យនោះមិនបានដឹង ហើយទើបតែស្រាវជ្រាវឃើញថ្មីៗនេះដោយអ្នកវិទ្យាសាស្រ្ត។ ឧ. ទឹកគឺជាប្រភពនៃភាវៈមានជីវិតទាំងឡាយ(*គួរអាន២១:៣០*),ការរីកមាឌនៃសាកលោក(*គួរអាន៥១:៤៧*) ,គន្លងរៀងខ្លួននៃព្រះអាទិត្យ និងព្រះចន្ទ(*គួរអាន២១:៣៣*)។ល។
- ផ្ទុកទៅដោយប្រវត្តិសាស្រ្តពិត ដែលមនុស្សជំនាន់នោះមិនបានដឹង ហើយមានការព្យាករណ៍ពីព្រឹត្តិការណ៍អនាគតជាច្រើន ដែលក្រោយមកបានបង្ហាញថាត្រឹមត្រូវ។
- មិនមានកំហុសឆ្គង ឬបដិវាទកម្ម(ការខ្វែងគ្នា) ទោះជាវាត្រូវបានបញ្ចុះមកម្ដងបន្តិចៗចំណាយពេល២៣ឆ្នាំទើបរួចរាល់ ហើយគ្របដណ្ដប់លើប្រធានបទជាច្រើន។
- ត្រូវបានគាំពាររក្សា រាល់ពាក្យ រាល់វាក្យស័ព្ទ តាំងពីពេលដែលបានបញ្ចុះមកដំបូងជាភាសាអារ៉ាប់។ ខុសប្លែកពីគម្ពីរដទៃដែលមិនអាចរក្សាបាននូវភាសាដើមរបស់វា។
- សារមានលក្ខណៈសាកល, បរិសុទ្ធ និងសាមញ្ញ ដែលអំពាវនាវទៅដល់បញ្ញានៃមនុស្ស និង ភ្ជាប់ជាមួយជំនឿលើព្រះជាម្ចាស់ដែលមានគ្រប់ចេស្ដា។
- មានឥទ្ធិពលខ្លាំងជ្រាលជ្រៅចំពោះមនុស្ស។
- ត្រូវបានបញ្ចុះមកកាន់ព្យាការី មូហាំម៉ាត់ (សូមសុខសន្តិភាពកើតមានចំពោះលោក) ដែលគេដឹងថាជាអ្នកមិនចេះអក្សរ ប៉ុន្តែគម្ពីរអាល់គួរអានផ្ទុកទៅដោយរចនាប័ទ្មល្អឯកនៃភាសា ដែលសកលលោកទទួលស្គាល់ថាជាកំពូលវោហាស័ព្ទ និងសំនួនពាក្យ នៃភាសាអារ៉ាប់ និងសោភ័ណ្ឌភាពនៃភាសា។
- មានការបកស្រាយសមហេតុផល ចំពោះរឿងរ៉ាវអព្ភូតហេតុអស្ចារ្យ ប្លែកៗជាច្រើននៃគម្ពីរអាល់គួរអាន ថាវាពិតជាមកពីព្រះជាម្ចាស់ពិតមែន។

## ព្រះប្រទានការចង្អុលបង្ហាញ

ផ្អែកតាមចំណេះដឹងដែលថា យើងបានបង្កើតដោយព្រះដែលមានគ្រប់បញ្ញាញាណនោះ យើងរំពឹងថាទទួលបានការប្រាប់អោយដឹងពីគោលបំណងរបស់យើង។ តើយើងធ្វើដូចម្ដេចទើបដឹងថាព្រះទ្រង់រំពឹងអ្វីពីយើង? តើយើងរស់នៅក្នុងការសាកល្បង? ឬយើងបង្កើតគោលបំណងនៃជីវិតដោយខ្លួនឯង? តើយើងគ្រាន់តែទៅតាមគេតាមឯងប៉ុណ្ណោះ? មិនដូច្នេះទេ ព្រះបញ្ជូនព្យាការីជាច្រើន ព្រមទាំងការបើកបង្ហាញតាមរយៈគម្ពីដើម្បីប្រាប់យើងអោយបានដឹងពីគោលបំណងនៃជីវិតរបស់យើង។

ព្រះបានបញ្ជូនព្យាការីរាប់ពាន់នាក់ យ៉ាងហោចណាស់ព្យាការីម្នាក់សម្រាប់ប្រជាជាតិមួយ ដោយនាំមកនូវសារដូចៗគ្នាគឺ៖ *ត្រូវគោរពសក្ការៈទៅចំពោះព្រះតែមួយអង្គគត់ និងប្រណិបត្តិតាមការចង្អុលបង្ហាញរបស់ទ្រង់។* ព្យាការីទាំងនេះរាប់បញ្ចូលទាំងអាដាំ, នួហ, អ៊ីព្រហ៊ីម, មូសា, យេស៊ូ និង មូហាំម៉ាត់ (សូមសុខសន្តិភាពកើតមានចំពោះលោកទាំងអស់គ្នា)។

ព្យាការី មូហាំម៉ាត់ (សូមសុខសន្តិភាពកើតមានចំពោះលោក) លោកគឺជាព្យាការីចុងក្រោយបង្អស់។ លោកជាគម្រូដ៏ឥតខ្ចោះនៃភាពស្មោះត្រង់, យុត្តិធម៌, មេត្តាករុណា និង សេចក្ដីក្លាហាន។ លោកបានទទួលនូវវិវរណៈចុងក្រោយពីព្រះ គឺគម្ពីរអាល់គួរអាន ដើម្បីបង្ហាញពីរបៀបអនុវត្តនូវអ្វីដែលគម្ពីរបានបង្រៀន។

> *លោកយេស៊ូ ក៏ដូចជាព្យាការីឯទៀតដែរ លោកបង្ហាញបដិហារិយ៍ហើយ អំពាវនាវអោយគោរពសក្ការៈព្រះពិតតែមួយអង្គគត់។*
> *គួរអាន ១៩:៣៦*

គម្ពីរអាល់គួរអានគឺជាគម្ពីនៃការចង្អុលបង្ហាញនិងបកស្រាយពីគោលបំណងនៃជីវិតរបស់យើង, នរណាគឺជាព្រះ, សកម្មភាពដែលព្រះពេញព្រះទ័យ ឬមិនពេញព្រះទ័យ, រឿងរ៉ាវនិងមេរៀនរបស់ពួកព្យាការី, រឿងរ៉ាវស្ថានបរមសុខនិងស្ថាននរក និងថ្ងៃជំនុំជម្រះ។ មានបំណងជម្រះនូវការយល់ខុសពីលក្ខណៈធម្មជាតិនៃព្រះ។ ក៏ដូចជាជម្រះពីភាពមន្ទិល រវាងលក្ខណៈធម្មជាតិរបស់លោកយេស៊ូ ធៀបនឹងលក្ខណៈធម្មជាតិរបស់ព្រះជាម្ចាស់។